**គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម**

Agricultural Value Chain Competitiveness and Safety Enhancement Project (ACSEP)

**គម្រោងលេខ: ៥០២៦៤-០០២ (ឥណទានលេខ÷ ៤០១៣-CAM (COL))**

---

# សេចក្តីជូនដំណឹង
# ស្តីពីការជ្រើសរើស អ្នកបើកបរ

(Driver Recruitment)

គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម គឺជាគម្រោងដែលនឹងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងខ្សែសង្វាក់តម្លៃនៃផលិតផលកសិកម្មដែលមានលក្ខណៈប្រកួតប្រជែងមួយចំនួនមានដូចជា÷ ដំឡូងមី ផ្លែស្វាយ គ្រាប់ស្វាយចន្ទី បន្លែ និងមាន់ស្រុក នៅក្នុងខេត្តចំនួន០៦រួមមាន÷ ខេត្តកំពង់ចាម កំពង់ធំ ឧត្តរមានជ័យ ព្រះវិហារ សៀមរាប និងខេត្តត្បូងឃ្មុំ។ គម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់សហករណ៍កសិកម្មចំនួន 230 (ប្រហែល 27,000 គ្រួសារ) និងអាជីវកម្មកសិ- ឧស្សាហកម្មចំនួន 50 នៅក្នុងតំបន់គោលដៅ។

**និយ័តករបរធនបាលកិច្ច** ដែលជាអង្គភាពអនុវត្តគម្រោងសម្រាប់សមាសភាគទី១ សូមប្រកាសជ្រើសរើសអ្នកបើកបរចំនួន ០២រូប ដើម្បីបំពេញការងារជាអ្នកបើកបរនៅក្នុងអង្គភាពអនុវត្តគម្រោង។

## ១. បេក្ខជនទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

| | |
|---|---|
| **សញ្ជាតិ** | ជាជនជាតិខ្មែរ |
| **ភាសា** | ភាសាខ្មែរ (អាចសរសេរបាន) |
| **ការអប់រំ** | យ៉ាងហោចបានបញ្ចប់ថ្នាក់ចំណេះដឹងទូទៅភាសាខ្មែរ |
| **បទពិសោធន៍** | - មានបទពិសោធន៍ក្នុងការបើកបរចាប់ពី ២ ឆ្នាំឡើងទៅ<br>- មានប័ណ្ណបើកបរមានសុពលភាព<br>- ចេះបើកបរ និងប្រើប្រាស់រថយន្តស៊េរីទំនើបៗ<br>- មានជំនាញបើកបរល្អ និង ស្ទាត់ជំនាញ<br>- មានបទពិសោធន៍ធ្វើការជាមួយស្ថាប័នរដ្ឋ វិស័យឯកជន ឬសហគ្រាសផ្សេងៗ |
| **សមត្ថភាព** | - ចេះថែទាំរថយន្តអោយបានស្អាត និង មានសុវត្ថិភាព<br>- បើកបរជូនថ្នាក់ដឹកនាំ និងក្រុមការងារ<br>- ចេះអាន ចេះសរសេរ និងឆាប់យល់<br>- មានភាពរួសរាយ រាក់ទាក់ និងមានឆន្ទៈក្នុងការបំពេញការងារ<br>- មានពេលវេលាគ្រប់គ្រាន់បំពេញការងារពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ<br>- អាចធ្វើដំណើរទៅគ្រប់ទីតាំងអនុវត្តគម្រោង។ |
| **តម្រូវការផ្សេងៗ** | - មានកាយសម្បទារមាំមួន និង រហ័សរហួន<br>- មានសុខភាពល្អ |

| | |
|---|---|
| | - មានអត្តចរិតល្អ<br>- ស្មោះត្រង់<br>- ខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការងារ<br>- មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤០ឆ្នាំ |

**២.ភារកិច្ចទទួលខុសត្រូវ**

- បំពេញភារកិច្ចជាអ្នកបើកបរ នៅក្នុងអង្គភាពអនុវត្តគម្រោង ACSEP Output1
- បើកបរជូនថ្នាក់ដឹកនាំ និងក្រុមការងារគម្រោង
- រៀបចំ ចាត់ចែង គ្រប់គ្រង ថែទាំ និងប្រើប្រាស់រថយន្ត របស់អង្គភាពអោយបានល្អ
- រៀបចំសំណើសុំជួសជុលថែទាំជូនដល់ផ្នែករដ្ឋបាលទទួលបន្ទុក
- អត់ធ្មត់ និងមានទំនួលខុសត្រូវលើការងារ
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំ ចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំ។

**៣. លក្ខខណ្ឌនៃកិច្ចសន្យា និងប្រាក់ឧបត្ថម្ភៈ**

- រយៈពេលពាខែដំបូងចាត់ទុកជាការសាកល្បងការងារ
- កិច្ចសន្យានឹងត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ហើយអាចត្រូវបានវាយតម្លៃ និងបន្តកិច្ចសន្យាទៅឆ្នាំបន្ទាប់ទៀត ដោយផ្អែកលើតម្រូវការជាក់ស្តែង
- អ្នកបើកបរនឹងទទួលបានប្រាក់ខែចំនួន ៣០០ ដុល្លារ (បីរយដុល្លារ) ក្នុង១ខែ និងប្រាក់ឧបត្ថម្ភបេសកកម្មផ្សេងៗ ក្នុងករណីទៅបំពេញការងារតាមបណ្តាខេត្តគោលដៅ។

**៤. លក្ខខណ្ឌតម្រូវដាក់ពាក្យសុំចូលបម្រើការងារ**

- បំពេញពាក្យសុំចូលបម្រើការងារចំនួន ០១ច្បាប់ (ពាក្យសុំអាចរកបាននូវផ្នែករដ្ឋបាល អង្គភាពអនុវត្តគម្រោង)
- ប្រវត្តិរូបសង្ខេបចំនួន ០១ច្បាប់ ដោយភ្ជាប់នូវលេខទូរស័ព្ទ សម្រាប់ទំនាក់ទំនង
- ច្បាប់ចម្លងឯកសារយោងចំនួន ០១ច្បាប់ (សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ ឬសញ្ញាប័ត្របញ្ជាក់ការសិក្សា)

**៥. កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ**

- កាលបរិច្ឆេទចាប់ទទួលពាក្យចាប់ពីថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២២
- កាលបរិច្ឆេទឈប់ទទួលពាក្យចាប់ពីថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១៨:០០នាទី
- ទីតាំងដាក់ពាក្យគឺនៅអង្គភាពអនុវត្តគម្រោង ACSEP រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ។

ថ្ងៃចន្ទ ៣កើត១៨ ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ភ្នំពេញ, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០២២

**ប្រធានគម្រោង**

សុខ ដារ៉ា